wellspring

ទូរស័ព្ទ៖ (562) 579-2024
អ៊ីម៉ែល៖ Wellspring.Leasing@bridgehousing.com
ការិយាល័យទំនាក់ទំនងព័ត៌មានជួល៖
2338 E. Anaheim St. Suite 105, Long Beach, CA 90804.

Wellspring ជាសហគមន៍ដែលមានលំនៅចំនួន 88 យូនីត នៅក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា ដែលផ្តល់ជូនផ្ទះល្វែងមាន 1-, 2- និង 3 បន្ទប់គេង (BR)។ លំនៅដែលមានតម្លៃទាបសមរម្យនេះ ត្រូវបានសាងសង់ឡើងដោយសាជីវកម្មលំនៅ BRIDGE ដោយសហការជាមួយ អាជ្ញាធរក្រុងឡុងប៊ិច និងខោនធីឡូសអេនជឺឡេស។ លំនៅដែលមានតម្លៃទាបសមរម្យចំនួន 47 យូនីត ត្រូវបានកំណត់សម្រាប់ជួល ដោយផ្អែកលើអត្រា 40%, 50% ឬ 60% នៃAMI (ប្រាក់ចំណូលមធ្យមរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះ)។ លំនៅម្ភៃប្រាំពីរ (27) យូនីត ក្នុងចំណោម 47 យូនីតនេះ នឹងត្រូវបើកសម្រាប់ទទួលអ្នកជួលមកពីខោនធីឡូសអេនជឺឡេសទាំងមូល ហើយម្ភៃ (20) យូនីតផ្សេងទៀតនឹងត្រូវដាក់ជួល អនុលោមតាមគោលការណ៍របស់ក្រុងឡុងប៊ិច ស្តីពីជម្រើសលំនៅជាអាទិភាព។ លំនៅ 1 យូនីត នឹងត្រូវបម្រុងទុកសម្រាប់បុគ្គលិកប្រចាំការ។ យើងរំពឹងថា ការសាងសង់នេះនឹងត្រូវបញ្ចប់នៅរដូវស្លឹកឈើជ្រុះឆ្នាំ 2023 នេះ។ ក្នុងចំណោមលំនៅ 47 យូនីត 7 យូនីតដែលសាងសង់ឡើងសម្រាប់ជនពិការ និង 7 យូនីត សម្រាប់អ្នកជួលដែលមានបញ្ហាគថ្លង់។

សំណង់សម្រាប់សេវាកម្មរួមមាន៖ សាលសហគមន៍ ជាមួយនិងផ្ទះបាយ បន្ទប់បោកគក់ ចំណតយានយន្ត សេវាកម្ម Wi-Fi ឥតគិតថ្លៃនៅក្នុង ទីលានរួម ទីធ្លាធំទូលាយសម្រាប់សាច់អាំង និងកន្លែងលំហែ សួនច្បារសហគមន៍ សួនកុមារ និងការចាត់ចែងគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈនៅនឹងកន្លែង។ ថ្លៃជួលរួមបញ្ចូល ថ្លៃទឹកស្អាត និងសេវាកម្មប្រមូលសំរាម។ អ្នកជួល ត្រូវរ៉ាប់រងថ្លៃចំណាយផ្សេងទៀតទាំងអស់ ដែលរួមទាំង ថ្លៃអគ្គិសនី ទូរស័ព្ទ និងខ្សែកាប។

អំឡុងពេលសម្រាប់ការដាក់ពាក្យសុំជួលដែលមានតម្លៃទាបសមរម្យ 47 យូនីត នេះនៅ Wellspring គឺ ចាប់ពីថ្ងៃទី11 ខែកក្កដា ដល់ ថ្ងៃទី1 ខែសីហា។ ត្រូវដាក់ពាក្យសុំឱ្យបានត្រឹមម៉ោង 5 ល្ងាច ថ្ងៃទី1 ខែសីហា (ត្រាបញ្ជាក់ កាលបរិច្ឆេទ ផ្ញើតាមប្រៃសណីយ៍ នឹងមិនចាត់ទុកជាបានការឡើយ)។ គ្រួសារមួយ មានសិទ្ធិដាក់ពាក្យសុំជួលជាមុន តែមួយប៉ុណ្ណោះ ពាក្យសុំស្ទួន នឹងត្រូវបដិសេធ។

| ទំហំ យូនីត | លេខ យូនីត | កម្រិត AMI | ថ្លៃជួល ប្រចាំខែ * | តម្រូវការប្រាក់ចំណូលអប្បរមា * * | ចំនួនអ្នកស្នាក់នៅ |
|---|---|---|---|---|---|
| 1 បន្ទប់គេង | 7 | 40% | $874 | $20,976 | 1 – 3 នាក់ |
| 1 បន្ទប់គេង | 5 | 50% | $1,110 | $26,640 | |
| 2 បន្ទប់គេង | 12 | 40% | $1,049 | $25,176 | 2 – 5 នាក់ |
| 2 បន្ទប់គេង | 6 | 50% | $1,332 | $31,968 | |
| 2 បន្ទប់គេង | 2 | 60% | $1,616 | $38,784 | |
| 3 បន្ទប់គេង | 8 | 40% | $1,203 | $28,872 | 3 – 7 នាក់ |
| 3 បន្ទប់គេង | 5 | 50% | $1,531 | $36,744 | |
| 3 បន្ទប់គេង | 2 | 60% | $1,859 | $44,616 | |

ក្រោយកាលបរិច្ឆេទបិទបញ្ចប់ការទទួលពាក្យសុំ នឹងមានការចាប់ឆ្នោតតាមកុំព្យូទ័រដើម្បីយកពាក្យសុំពីក្នុងបញ្ជីនីមួយៗ មកពិនិត្យ ហើយរាល់ពាក្យសុំជាមុន ដែលទទួលបានមុនកាលកំណត់ នឹងត្រូវចាប់យកដោយចៃដន្យ។ បន្ទាប់ពីនេះ នឹងមានការជូនដំណឹងដល់អ្នកដាក់ពាក្យសុំ អំពីលេខឆ្នោតរបស់ពួកគេ។ ការផ្តល់ជូនផ្ទះល្វែងទាំងនេះសម្រាប់ជួល នឹងផ្អែកលើគោលការណ៍អ្នកដាក់ពាក្យសុំជួលបំពេញតាមលក្ខខណ្ឌតម្រូវបានមុនគេនឹងបានផ្តល់ជូនផ្ទះល្វែងមុនគេ។

**ប្រាក់ចំណូលដុលអតិបរមាប្រចាំឆ្នាំ គិតតាមចំនួនមនុស្សក្នុងគ្រួសារ**

| ចំនួនមនុស្សក្នុងគ្រួសារ | 40% AMI | 50% AMI | 60% AMI |
|---|---|---|---|
| 1 នាក់ | $35,320 | $44,150 | n/a |
| 2 នាក់ | $40,360 | $50,450 | $60,540 |
| 3 នាក់ | $45,400 | $56,750 | $68,100 |
| 4 នាក់ | $50,440 | $63,050 | $75,660 |
| 5 នាក់ | $54,480 | $68,100 | $81,720 |
| 6 នាក់ | $58,520 | $73,150 | $87,780 |
| 7 នាក់ | $62,560 | $78,200 | $93,840 |

* ថ្លៃជួល និងកម្រិតប្រាក់ចំណូល អាចនឹងត្រូវកែប្រែ។ ថ្លៃជួល គិតបញ្ចូល ថ្លៃទឹកស្អាត និងថ្លៃប្រមូលសម្រាម។ អ្នកជួល ត្រូវរ៉ាប់រងបន្ទុក ចំណាយផ្សេងទៀតទាំងអស់ ដែលរួមទាំង ថ្លៃអគ្គិសនី ទូរស័ព្ទ និងខ្សែកាប។ ** ពុំមានលក្ខខណ្ឌអំពីកម្រិតប្រាក់ចំណូលអប្បបរមាឡើយ សម្រាប់អ្នកដាក់ពាក្យដែលមានបណ្ណសេចសិន 8 (Section 8)។

The sentence below is a reminder that translation assistance is available
Si Ud necesita ayuda para traducir esta información al español, por favor llame al número de la oficina o pase por la oficina del Gerente.

បន្ទាប់ពីបានទទួលពាក្យសុំសម្រាប់យូនីតទាំងអស់នៅក្នុងការដាក់ជួលដំបូងហើយនោះ នឹងមានការបង្កើតបញ្ជីរង់ចាំអេឡិចត្រូនិចមួយសម្រាប់យូនីតដែលគ្មានជំនួយឧបត្ថម្ភ។ គណៈគ្រប់គ្រងលំនៅនេះសូមរក្សាសិទ្ធិក្នុងការកាត់ចេញឈ្មោះក្នុងបញ្ជីរង់ចាំ រហូតដល់ 500 គ្រួសារ (ផ្អែកតាមលេខឆ្នោត) បន្ទាប់ពីជួលអស់។ អ្នកដាក់ពាក្យសុំដទៃទៀត នឹងបានទទួលព័ត៌មានថា ពាក្យសុំជាមុនរបស់ពួកគេពុំស្ថិតក្នុងបញ្ជីរង់ចាំទៀតឡើយ។ នៅពេលបើកបញ្ជីរង់ចាំជាថ្មីនាពេលអនាគត អ្នកដាក់ពាក្យសុំទាំងនេះ ស្វាគមន៍ការដាក់ពាក្យឡើងវិញ។

ហេតុផលមួយដែលយើងអាចផ្តល់ជូនផ្ទះល្វែងទាំងនេះ សម្រាប់ជួលក្នុងតម្លៃទាប គឺដោយសារយើងបានទទួលការឧបត្ថម្ភ មួយផ្នែកពី **កម្មវិធីរបស់រដ្ឋាភិបាលសហព័ន្ធ ដែលហៅថា កម្មវិធីឥណទានលំនៅសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប** (LIHTC)។ ការឧបត្ថម្ភពីកម្មវិធីនេះ ក៏ដូចជាពីប្រភពផ្សេងទៀតផងដែរ ត្រូវបានប្រើប្រាស់ដើម្បីសាងសង់លំនៅទាំងនេះ ដែលតម្រូវឱ្យអ្នកគ្រប់គ្រងធ្វើការជ្រើសរើសអ្នកដាក់ពាក្យទាំងអស់ដោយប្រុងប្រយ័ត្ន។ អ្នកដាក់ពាក្យសុំ ត្រូវតែបំពេញបានតាមលក្ខខណ្ឌ ដោយផ្អែកលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានព្យាករណ៍ (ដែលរួមទាំង ទ្រព្យទាំងអស់) ចំនួនមនុស្សក្នុងគ្រួសារ ក្រេឌីត និងប្រវត្តិនៃការជួល។ កម្មវិធី LIHTC ក៏មានការរឹតត្បិតដែលទាក់ទងនឹងនិស្សិតពេញម៉ោង ដែលតម្រូវឱ្យមានការពិនិត្យប្រចាំត្រីមាស ឬ ឆមាសផងដែរ។ ដំណើរការពិនិត្យ និងផ្ទៀងផ្ទាត់នេះត្រូវបានអនុវត្តដូចគ្នាចំពោះអ្នកដាក់ពាក្យគ្រប់រូប។

ត្រូវបំពេញពាក្យសុំទាំងអស់ឱ្យបានពេញលេញ ទើបអាចទទួលការពិនិត្យសម្រាប់ការផ្តល់ជូនផ្ទះល្វែង។ ការផ្តល់ជូនផ្ទះល្វែងទាំងនេះសម្រាប់ជួលនឹងផ្អែកលើគោលការណ៍ អ្នកដាក់ពាក្យសុំជួលបំពេញតាមលក្ខខណ្ឌតម្រូវបានមុនគេនឹងបានផ្តល់ជូនផ្ទះល្វែងមុនគេ។ អ្នកដាក់ពាក្យសុំ ត្រូវធ្វើការជិតស្និទ្ធជាមួយសហការីផ្នែកជួល ដើម្បីអនុវត្តដំណើរការដាក់ពាក្យសុំឱ្យបានពេញលេញ និងឆាប់រហ័សតាមដែលអាចធ្វើបាន ហើយយើងស្វាគមន៍រាល់មតិយោបល់កែលំអនានាដែលអាចមាន ទាក់ទងនឹងដំណើរការនេះ។

## សត្វចិញ្ចឹម

យើងអនុញ្ញាតឱ្យមានការចិញ្ចឹមសត្វ នៅក្នុងសហគមន៍នេះ។ ម្ចាស់សត្វទាំងនេះត្រូវកក់ប្រាក់ចំនួន 300 ដុល្លារ និងត្រូវចុះកិច្ចព្រមព្រៀងមួយអំពីសត្វចិញ្ចឹមទាំងនេះ។ សូមទាក់ទងអ្នកគ្រប់គ្រង ប្រសិនបើលោកអ្នក មានសត្វចិញ្ចឹមបែបនេះ។

## ចំណតរថយន្ត

យើងមានទំហំទីធ្លាក្នុងកម្រិតកំណត់សម្រាប់អ្នកជួលនៅទីនេះហើយយើងក៏មិនអាចធានាវត្តមានកន្លែងចតរថយន្តគ្រប់គ្រាន់ឡើយ។ មានតែរថយន្តរបស់អ្នកជួលនៅទីនេះប៉ុណ្ណោះ ដែលអាចអនុញ្ញាតឱ្យចតបាន។ អ្នកជួលនៅទីនេះត្រូវចុះឈ្មោះសម្រាប់រថយន្តរបស់ខ្លួន និងត្រូវផ្តល់ភស្តុតាងនៃការធានារ៉ាប់រងរថយន្តនាពេលបច្ចុប្បន្ន រួមជាមួយបណ្ណបើកបរដែលមានសុពលភាពផងដែរ។ រថយន្តទាំងអស់សម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ ដែលស្ថិតក្នុងស្ថានភាពអាចប្រើការបាន និងមានការថែទាំបានត្រឹមត្រូវដើម្បីធានាសុវត្ថិភាពគ្រប់ពេលវេលា។ យានយន្តដែលមិនបំពេញតាមលក្ខខណ្ឌទាំងនេះ នឹងត្រូវអូសចេញដោយម្ចាស់ត្រូវទទួលបន្ទុកថ្លៃចំណាយ។ នេះជាលក្ខខណ្ឌដែលគ្មានការលើកលែង។ យើងអាចមានកន្លែងសម្រាប់ចត តែគ្មានការកំណត់ទុកឡើយ។

## សេចក្តីបញ្ជាក់អំពីការមិនរើសអើង

គោលដៅរបស់ Wellspring គឺធានាថា អ្នកដាក់ពាក្យទាំងអស់ត្រូវបានពិនិត្យដោយប្រើលក្ខណៈវិនិច្ឆ័យដែលគ្មានលំអៀង និងការរាប់អានគ្នាដើម្បីផ្តល់កន្លែងសមស្របសម្រាប់ការរស់នៅដែលថែទាំបានល្អ និងមានតម្លៃទាបសមរម្យសម្រាប់ពលរដ្ឋចម្រុះអំបូរ និងជាតិសាសន៍ រស់នៅដោយគ្មានភាពខ្វះខាត ទន្ទឹមនឹងគោរពតាមបទប្បញ្ញត្តិនៃច្បាប់សហព័ន្ធ រដ្ឋ ឬ មូលដ្ឋាន ដែលហាមឃាត់ការរើសអើងក្នុងការទទួលបានលំនៅដោយសារតែពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា សញ្ជាតិពីកំណើត ពិការភាព ស្ថានភាពគ្រួសារ ស្ថានភាពអាពាហ៍ពិពាហ៍ ប្រភពចំណូល និន្នាការផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬ អ្នកកាន់បណ្ណទូទាត់ (ជំនួយឧបត្ថម្ភសម្រាប់ការជួល) ។

**សម្រាប់ទំនាក់ទំនងព័ត៌មាន៖**

ទូរស័ព្ទ៖ (562) 579-2024

អ៊ីម៉ែល៖ Wellspring.Leasing@bridgehousing.com

អាសយដ្ឋានប្រៃសណីយ៍៖

Wellspring
PO Box 4870
Long Beach, CA 90804

# Wellspring - ជម្រើសយកអ្នកមកពីក្រុងឡុងប៊ិច

ផ្ទះល្វែងចំនួនម្ភៃប្រាំពីរ (27) យូនីត នឹងត្រូវបើកដើម្បីទទួលអ្នកជួលមកពីខោនធីឡូសអេនជឺឡេសទាំងមូល ហើយផ្ទះចំនួនម្ភៃ(20) យូនីតផ្សេងទៀត នឹងត្រូវដាក់ជួល អនុលោមតាមគោលការណ៍របស់ក្រុងឡុងប៊ិចស្តីពី ជម្រើសលំនៅជាអាទិភាព។ ជម្រើសទាំងនេះ ជាកត្តាកំណត់ពីលេខលំដាប់ដែលក្រុមហ៊ុនត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ សម្រាប់ដំណើរការចាត់ចែងឯកសារជួល។ អ្នកដាក់ពាក្យសុំ នៅតែត្រូវបំពេញឱ្យបានតាមលក្ខខណ្ឌតម្រូវសម្រាប់ការជួលនេះ។

លោកអ្នកអាចកំណត់យកជម្រើសណាមួយសម្រាប់ពាក្យសុំរបស់ខ្លួន។ លោកអ្នកពុំចាំបាច់កំណត់យកជម្រើសណាមួយឡើយនៅលើពាក្យសុំរបស់ខ្លួន នៅក្នុងអំឡុងពេលនៃការដាក់ពាក្យនៅពេលដំបូង។

ប្រសិនបើលោកអ្នកកំណត់យកជម្រើសណាមួយ ហើយត្រូវបានបុគ្គលិកខាងផ្នែកជួលទាក់ទងមកដើម្បីបន្តដំណើរការនៃការចាត់ចែងឯកសារជួល លោកអ្នកត្រូវផ្តល់ភស្តុតាងអំពីជម្រើសរបស់ខ្លួន សម្រាប់ការសម្ភាស។ ប្រសិនបើលោកអ្នកមិនអាចផ្តល់ឯកសារអំពីជម្រើសរបស់ខ្លួនទេនោះ ក្រុមហ៊ុននឹងចាត់ទុកពាក្យសុំរបស់លោកអ្នក ជាពាក្យសុំដែលគ្មានការកំណត់ជម្រើសណាមួយឡើយ។

ផ្ទះចំនួន 20 យូនីត ត្រូវបានត្រៀមបម្រុងសម្រាប់អ្នកដាក់ពាក្យ តាមលំដាប់ដូចខាងក្រោម៖

1. **កន្លែងស្នាក់នៅបច្ចុប្បន្ន៖** គ្រួសារដែលយ៉ាងហោចណាស់មានសមាជិកណាម្នាក់ដែលទទួលខុសត្រូវលើការជួល ត្រូវតែមានកន្លែងស្នាក់នៅចម្បងរបស់ខ្លួន ស្ថិតនៅក្នុងទីក្រុងឡុងប៊ិច គិតចាប់ពីថ្ងៃដាក់ពាក្យសុំ។

   ដើម្បីបញ្ជាក់អំពីជម្រើសនេះ យ៉ាងហោចណាស់សមាជិកម្នាក់នៃគ្រួសារ ត្រូវដាក់ជូនឯកសារណាមួយដូចខាងក្រោម ដែលបង្ហាញពីអាសយដ្ឋានបច្ចុប្បន្ននៃលំនៅរបស់ខ្លួនស្ថិតនៅក្នុងក្រុងឡុងប៊ិច៖
   - បណ្ណបើកបរបច្ចុប្បន្ន
   - បណ្ណចុះឈ្មោះអ្នកបោះឆ្នោត
   - បណ្ណបង់ប្រាក់សន្តិសុខសង្គមឬឯកសារបច្ចុប្បន្នដែលបង្ហាញថា អ្នកដាក់ពាក្យសុំ គឺជាម្ចាស់បណ្ណនោះ
   - កិច្ចព្រមព្រៀងជួលបច្ចុប្បន្នដែលមានឈ្មោះរបស់អ្នកដាក់ពាក្យសុំ
   - វិក្កយបត្រពន្ធលើអចលនទ្រព្យ និងឈ្មោះរបស់អ្នកដាក់ពាក្យសុំនៅលើបណ្ណកម្មសិទ្ធិនោះ
   - វិក្កយបត្រសេវាកម្ម (ឧ. ទឹក ហ្គាស អគ្គិសនី) មានឈ្មោះរបស់អ្នកដាក់ពាក្យសុំ ជាមួយអាសយដ្ឋានសេវាកម្មដែលបង្ហាញអាសយដ្ឋាននៅក្នុងក្រុងឡុងប៊ិច

2. **ការងារ៖** គ្រួសារដែលមានសមាជិកយ៉ាងតិចម្នាក់ ដែលទទួលខុសត្រូវលើការជួល ត្រូវតែមានការងារនៅក្នុងក្រុងឡុងប៊ិច ដោយជូនដំណឹងថា ពួកគាត់មានការងារធ្វើនៅក្រុងឡុងប៊ិច ឬ បានចុះឈ្មោះក្នុងកម្មវិធីអប់រំ ឬ បណ្តុះបណ្តាលការងារយ៉ាងសកម្មនៅក្រុងឡុងប៊ិច គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំ។ (ជម្រើសនេះមិនអាចអនុវត្តចំពោះនិស្សិតឡើយ ប្រសិនបើពួកគេកំពុងរស់នៅជាមួយឪពុកម្តាយ នៅពេលដាក់ពាក្យ ឬ ជ្រើសរើស។)
   ដើម្បីបញ្ជាក់ពីជម្រើសនេះ សមាជិកណាម្នាក់ក្នុងគ្រួសារ ត្រូវដាក់ជូនឯកសារណាមួយដូចខាងក្រោម ជាមួយឈ្មោះរបស់ខ្លួន។
   - បង្កាន់ដៃបញ្ជាក់ប្រាក់កម្រៃរបស់ខ្លួន
   - ឯកសារ W-2 ឬ ឯកសារបង់ពន្ធ
   - តារាងប្រាក់កម្រៃពីនិយោជក
   - ភស្តុតាងគ្រប់គ្រាន់ពីកន្លែងសិក្សា ឬ ការបណ្តុះបណ្តាលការងារ ដែលបានចុះឈ្មោះចូលរៀនយ៉ាងសកម្មនៅក្នុងកម្មវិធីសិក្សា ឬ បណ្តុះបណ្តាលក្នុងការងារ។

   ពួកគេក៏ត្រូវបញ្ជាក់ផងដែរថា និយោជករបស់ខ្លួនជាអ្នកក្នុងមូលដ្ឋាន ដោយដាក់ជូនឯកសារណាមួយដូចតទៅ៖
   - អាជ្ញាបណ្ណអាជីវកម្ម ចេញដោយអាជ្ញាធរក្រុងឡុងប៊ិច
   - លិខិតពីនិយោជកដែលបញ្ជាក់អាសយដ្ឋានអាជីវកម្ម
   - អាសយដ្ឋានអាជីវកម្មដែលមានចុះនៅក្នុងសៀវភៅលេខទូរស័ព្ទ
   - ភស្តុតាងផ្សេងទៀត ដែលបញ្ជាក់ពីការចុះឈ្មោះនៅកន្លែងបណ្តុះបណ្តាល/អប់រំការងារក្នុងក្រុងឡុងប៊ិច។

# ដំណើរការដាក់ពាក្យ

សូមអរគុណចំពោះការចាប់អារម្មណ៍លើអចលនទ្រព្យនេះ។ សូមពិនិត្យមើលជំហានខាងក្រោមដើម្បីយល់ពីឯកសារដែលលោកអ្នកត្រូវបញ្ជូនមក សម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការជ្រើសរើស។

**ដើម្បីដាក់ពាក្យសុំជួលអចលនទ្រព្យនេះ៖**
សូមដាក់ស្នើពាក្យសុំដែលបានបំពេញត្រឹមត្រូវ ដែលចុះហត្ថលេខាដោយមនុស្សពេញវ័យគ្រប់រូប (18+ឆ្នាំ) តាមប្រព័ន្ធអនឡាញ ឬ តាមប្រៃសណីយ៍។

អ្នកដាក់ពាក្យសុំទាំងអស់ត្រូវបំពេញពាក្យសុំជាមុន។ ក្រោយថ្ងៃផុតកំណត់ដាក់ពាក្យសុំ រាល់ពាក្យសុំនឹងត្រូវជ្រើសយកដោយចៃដន្យតាមកុំព្យូទ័រសម្រាប់ការពិនិត្យ និងកំណត់លេខលំដាប់។ សូមចាំថា ក្រុមហ៊ុននឹងផ្តល់ជូនផ្ទះល្វែងទាំងនេះសម្រាប់ជួលនឹងផ្អែកលើគោលការណ៍ អ្នកដាក់ពាក្យសុំជួលបំពេញតាមលក្ខខណ្ឌតម្រូវបានមុនគេនឹងបានផ្តល់ជូនផ្ទះល្វែងមុនគេ។

**ដំណើរការចាត់ចែងឯកសារ - ការសម្ភាសអំពីលក្ខខណ្ឌតម្រូវ**
នៅពេលលោកអ្នកបានទទួលដំណឹងថា ដល់វេនត្រូវពិនិត្យឯកសាររបស់ខ្លួន លោកអ្នកត្រូវមកជួបភ្នាក់ងារជួលរបស់យើង ហើយដាក់ជូនឯកសារដូចមានរាយនៅទំព័របន្ទាប់។ ការត្រួតពិនិត្យក្រេឌីត ការពិនិត្យប្រវត្តិបទព្រហ្មទណ្ឌកន្លងមក ឯកសារយោងពីម្ចាស់ផ្ទះ និងការផ្ទៀងផ្ទាត់ប្រាក់ចំណូល និងទ្រព្យសម្បត្តិ គឺជាលក្ខខណ្ឌតម្រូវសម្រាប់អ្នកដាក់ពាក្យសុំទាំងអស់។ ការជួបពិភាក្សានេះនឹងផ្តល់ឱកាសឱ្យលោកអ្នកសួរសំណួរ ដែលអាចទាក់ទងនឹងដំណើរការដាក់ពាក្យសុំ និងអចលនទ្រព្យនេះ។ តាមធម្មតាការសម្ភាសនេះត្រូវចំណាយពេលប្រហែលមួយម៉ោង ហើយអាចតម្រូវឱ្យមានការជួបជាបន្តផងដែរ។ ចំពោះអ្នកទាំងអស់ដែលគ្រោងរស់នៅក្នុងផ្ទះល្វែងនេះ ដោយមិនគិតពីអាយុ ត្រូវតែចូលរួមក្នុងការសម្ភាសនេះ។ យើងសូមឱ្យលោកអ្នករក្សាការអត់ធ្មត់ និងផ្តល់កិច្ចសហការជាមួយយើង។

1. ដាក់ជូន**ពាក្យសុំពេញលេញ** រួមទាំង ចុះហត្ថលេខា ដែលតម្រូវសម្រាប់អ្នកដាក់ពាក្យសុំគ្រប់រូបដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។
2. ដាក់ជូន**កស្តុតាងអំពីជម្រើស**ណាមួយដូចមានចុះក្នុងផ្នែកខាងលើ ប្រសិនបើចង់ប្រើជម្រើសនោះ។
3. **បង់ថ្លៃពាក្យសុំដែលមិនអាចដកវិញបានចំនួន 25 ដុល្លារ** សម្រាប់អ្នកដាក់ពាក្យគ្រប់រូបដែលមានអាយុ 18 ឆ្នាំឡើងមកឱ្យ Wellspring (ជាមូលប្បទានប័ត្រធានាដោយធនាគារ ឬបណ្ណបញ្ញាទិញសាច់ប្រាក់តែប៉ុណ្ណោះ។ យើងសូមរក្សាសិទ្ធិមិនទទួលយកមូលប្បទានប័ត្រផ្ទាល់ខ្លួន ឬសាច់ប្រាក់ទេ)។
4. កំណត់ពេល**សម្ភាសន៍**ជាមួយសហការីផ្នែកជួល។

**ការផ្តល់ជូនផ្ទះល្វែង**
នៅពេលបានទទួលឯកសារទាំងអស់ បានផ្ទៀងផ្ទាត់ និងអនុម័តរួចហើយ អ្នកដាក់ពាក្យសុំដែលបំពេញលក្ខខណ្ឌបានគ្រប់គ្រាន់ នឹងត្រូវអញ្ជើញឱ្យត្រឡប់មកមើលផ្ទះល្វែងដែលត្រូវបានជ្រើសរើសសម្រាប់ពួកគាត់។ សូមចាំថា អ្នកនឹងទទួលបានការផ្តល់ជូនផ្ទះល្វែងតែមួយគត់សម្រាប់ការជួលនេះ។ រាល់ការផ្តល់ជូន នឹងត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកបដិសេធផ្ទះល្វែងនោះ អ្នកនឹងត្រូវចាត់ទុកថាបានដកពាក្យសុំរបស់ខ្លួន។

**ការជួលត្រូវមានរយៈពេល 12 ខែ**
ការជួលត្រូវមានរយៈពេលអប្បបរមាមួយឆ្នាំ។

WELLSPRING

# ហេតុផលនៃការបដិសេធពាក្យសុំជួល

អ្នកដាក់ពាក្យម្នាក់ៗ មានភារៈទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានណាមួយ និងព័ត៌មានទាំងអស់ ដែលត្រូវការជាចាំបាច់ ដើម្បីកំណត់អំពីសិទ្ធិក្នុងការជួល។ ចំណុចនានាដូចខាងក្រោមនេះ បង្ហាញពីមូលហេតុដែលយើងអាចបដិសេធពាក្យសុំរបស់លោកអ្នកៈ

១. **ឥណទាន** (កម្ចីនិសិត្ស និងថ្លៃព្យាបាលពុំរាប់បញ្ចូលបានឡើយ)

ក. បញ្ហាឥណទានសរុបដែលបំពេញមិនបាន (រាប់បញ្ចូលទាំង បំណុលពន្ធរបស់រដ្ឋាភិបាល ពន្ធបង់មិនទាន់គ្រប់ គណនីហួសកាលកំណត់ និងសមតុល្យនៃការបិទគណនី) ក្នុងរយៈពេលបី (៣) ឆ្នាំចុងក្រោយនេះ ដែលមានចំនួនលើស $ ២,៥០០។

ខ. ការក្ស័យធន (ក្នុងរយៈពេលបីឆ្នាំចុងក្រោយ)។

គ. បញ្ហាឥណទានសរុបចំនួនប្រាំពីករណី ដែលបំពេញមិនបាន (រាប់បញ្ចូលទាំង បំណុលពន្ធរបស់រដ្ឋាភិបាល ពន្ធបង់មិនទាន់គ្រប់ គណនីហួសកាលកំណត់ និងសមតុល្យនៃការបិទគណនី) ក្នុងចំនួនណាមួយ ក្នុងរយៈពេលបី (៣) ឆ្នាំចុងក្រោយនេះ។

ឃ. អ្នកដាក់ពាក្យសុំទាំងអស់ដែលមិនបំពេញបាន តាមលក្ខណៈវិនិច្ឆ័យខាងលើ នឹងបានទទួលលិខិតបដិសេធ ដែលបង្ហាញពីហេតុផលជាក់លាក់សម្រាប់ការបដិសេធ។ លិខិតនេះនឹងរួមបញ្ចូលការណែនាំសម្រាប់ការប្តឹងតវ៉ាចំពោះការបដិសេធនោះ។

២. **សាវតានៃការជួល**

ក. សាលក្រមដែលម្ចាស់ផ្ទះបច្ចុប្បន្ន ឬ ពីមុនបានទទួល ទាក់ទងនឹងការដាក់បន្ទុកជំទាស់អ្នកដាក់ពាក្យសុំ ក្នុងរយៈពេលបី (៣) ឆ្នាំចុងក្រោយនេះ។

ខ. កាតព្វកិច្ចដែលមិនទាន់បំពេញចំពោះការជំពាក់ម្ចាស់ផ្ទះមុន ក្នុងរយៈពេលបី (៣) ឆ្នាំចុងក្រោយនេះ។

គ. អ្នកដាក់ពាក្យត្រូវតែបានបង់ថ្លៃជួលទាន់ពេលវេលាទៅម្ចាស់ផ្ទះ សម្រាប់បណ្តាឆ្នាំមុនៗ។

៣. **ប្រវត្តិផ្ទាល់ខ្លួន**

ក. ឯកសារសាវតាអំពីអំពើហិង្សា ឬ ការរំលោភបំពាន (រាងកាយ ឬ ពាក្យសំដី) ដែលបានកំណត់ថា អ្នកដាក់ពាក្យសុំបានសំដែងឱ្យឃើញ ជាការគំរាមកំហែងចំពោះសុខភាព សុវត្ថិភាព ឬ សិទ្ធិទទួលបានភាពរីករាយដោយសន្តិវិធី របស់អ្នកផ្សេងទៀត ឬ និយោជិត និងអ្នកម៉ៅការដែលធ្វើការក្នុងគម្រោងនេះ។

ខ. បច្ចុប្បន្ន មានសេពគ្រឿងស្រវឹង ឬ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ ការប្រើប្រាស់ទាំងនេះនឹងត្រូវចាត់ជាការប្រើថ្នាំខុសច្បាប់ (លើកលែងមានការផ្ទៀងផ្ទាត់របស់វេជ្ជបណ្ឌិត)។

៤. **ការពិនិត្យមើលសាវតានៃបទព្រហ្មទណ្ឌ**

ក. តើសមាជិកពេញវ័យណាម្នាក់ក្នុងគ្រួសារ ត្រូវបានចាត់ជាកម្មវត្ថុនៃបទល្មើសផ្លូវភេទពេញមួយជីវិតដោយរដ្ឋណាមួយឬទេ។

ខ. ការផ្តន្ទាទោសចំពោះសកម្មភាពហឹង្សាដែលចាត់ជាបទព្រហ្មទណ្ឌ ដែលគំរាមកំហែងចំពោះសុខភាព សុវត្ថិភាព ឬ សិទ្ធិទទួលបានភាពរីករាយដោយសន្តិវិធី របស់អ្នកផ្សេងទៀត ឬ និយោជិត និងអ្នកម៉ៅការដែលធ្វើការក្នុងគម្រោងនេះ។

គ. ការផ្តន្ទាទោសចំពោះសកម្មភាពដែលចាត់ជាបទព្រហ្មទណ្ឌ ទាក់ទងនឹងគ្រឿងញៀន ដែលគំរាមកំហែងចំពោះសុខភាព សុវត្ថិភាព ឬ សិទ្ធិទទួលបានភាពរីករាយដោយសន្តិវិធី របស់អ្នកផ្សេងទៀត ឬ និយោជិត និងអ្នកម៉ៅការដែលធ្វើការក្នុងគម្រោងនេះ។

ឃ. ការផ្តន្ទាទោសនៅក្រោមបទព្រហ្មទណ្ឌផ្សេងទៀតដែលៈ ១)គំរាមកំហែងចំពោះសុខភាព សុវត្ថិភាព ឬសិទ្ធិទទួលបានការរីករាយដោយសន្តិវិធី របស់អ្នកផ្សេងទៀត ឬ និយោជិត និងអ្នកម៉ៅការដែលធ្វើការក្នុងគម្រោងនេះ។ ឬ ២) ទាក់ទងដោយផ្ទាល់ជាមួយកាតព្វកិច្ចខាងហិរញ្ញវត្ថុ។

ង. ទាក់ទងនឹងការឃាត់ខ្លួនដែលមិនទាន់ដោះស្រាយ (បទព្រហ្មទណ្ឌ ឬ ការកាត់ក្តីនៅក្នុងការស៊ើបអង្កេត ដែលមិនទាន់បានដោះស្រាយ)៖ ប្រភេទ និងកម្រិតធ្ងន់ធ្ងរនៃការប្រព្រឹត្តដែលគួសបញ្ជាក់ពីប្រវត្តិនៃការចោទប្រកាន់ នឹងត្រូវយកមកពិចារណា ប្រសិនបើការឃាត់ខ្លួនដែលនៅមិនទាន់ដោះស្រាយនោះ ទាក់ទងនឹង (ក) បទល្មើសគ្រឿងញៀន (ខ) បទព្រហ្មទណ្ឌលើជនដទៃ (គ) បទល្មើសផ្លូវភេទ (ឃ) បទព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងការក្លែងបន្លំហិរញ្ញវត្ថុ រួមទាំងការលួចអត្តសញ្ញាណ និងការក្លែងបន្លំ ឬ (ង) បទព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើការប្រព្រឹត្តរបស់អ្នកដាក់ពាក្យសុំនោះត្រូវបានដាក់បន្ទុក ឬ ការចោទប្រកាន់មានលក្ខណៈដែលបង្កការប៉ះពាល់ធ្ងន់ធ្ងរចំពោះ៖ (i) ទ្រព្យសម្បត្តិរបស់ម្ចាស់ផ្ទះ ឬ អ្នកជួល ឬ (ii) សុខភាព សុវត្ថិភាព ឬ សិទ្ធិទទួលបានភាពរីករាយដោយសន្តិវិធីរបស់អ្នកផ្សេងទៀត ម្ចាស់ផ្ទះ ឬ ភ្នាក់ងាររបស់ម្ចាស់ផ្ទះ។

ក្នុងការសម្រេចចិត្តដោយផ្អែកលើសារៈតានៃបទព្រហ្មទណ្ឌ BPMC អាចធ្វើការវាយតម្លៃដោយឡែក ដោយផ្អែកលើព័ត៌មានក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយ គិតចាប់ពីថ្ងៃដាក់ពាក្យ ដោយរួមបញ្ចូលតែការចោទប្រកាន់ដែលទាក់ទងដោយផ្ទាល់ និងការឃាត់ខ្លួនដែលនៅពុំទាន់បានដោះស្រាយ ពេលវេលាដែលបានកន្លងផុតសម្រាប់ការផ្តន្ទាទោស ឬ ការចាប់ខ្លួនដែលនៅពុំទាន់បានដោះស្រាយ ភស្តុតាងនៃភាពមិនត្រឹមត្រូវណាមួយក្នុងព័ត៌មានដែលបានរាយការណ៍ ភស្តុតាងនៃការស្តារនីតិសម្បទា និងកត្តាសម្រាលបន្ទុកផ្សេងទៀតដែលអ្នកដាក់ពាក្យអាចចង់ផ្តល់ជូន។

**៥. ប្រាក់ចំណូលប្រចាំឆ្នាំ/ ស្តង់ដារនៃចំនួនមនុស្ស/ បញ្ញត្តិនៃកម្មវិធីផ្សេងទៀត**

ក. ប្រាក់ចំណូលប្រចាំឆ្នាំ (រាប់បញ្ចូលទាំងទ្រព្យសកម្ម) ដែលមិនស្ថិតក្នុងលក្ខខណ្ឌដែលបានកំហិតសម្រាប់អចលនទ្រព្យនេះ។

ខ. ចំនួនមនុស្សក្នុងគ្រួសារ ត្រូវតែស្របតាមស្តង់ដានៃចំនួនមនុស្សស្នាក់នៅ ដែលបានកំណត់សម្រាប់អចលនទ្រព្យនេះ។

គ. អ្នកដាក់ពាក្យត្រូវតែបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវសម្រាប់កម្មវិធីដែលមានចែង។

**៦. ឯកសារ៖** អ្នកគ្រោងស្នាក់នៅទាំងអស់ ត្រូវផ្តល់គ្រប់ឯកសារចាំបាច់សម្រាប់ការជ្រើសរើស

ក. មិនបានមកជួបសម្រាប់ការសម្ភាស

ខ. ការមិនផ្តល់ពាក្យសុំដែលបានបំពេញ និងដែលបានចុះហត្ថលេខា ការចេញផ្សាយព័ត៌មាន ហេតុផលសម្រាប់ការបដិសេធ និងថ្លៃពាក្យសុំ (ប្រសិនបើចាំបាច់)។

គ. មិនផ្តល់ឯកសារយោងអំពីម្ចាស់ផ្ទះដែលខ្លួនបានស្នាក់នៅរយៈពេលបីឆ្នាំចុងក្រោយ។ *ចំណាំ៖ អ្នកដាក់ពាក្យសុំដែលគ្មានកិច្ចព្រមព្រៀងជួល សម្រាប់រយៈពេលយ៉ាងតិច ដប់ពីរខែ នៅក្នុងអំឡុងពេល បីឆ្នាំចុងក្រោយនេះ នឹងតម្រូវឱ្យផ្តល់ឯកសារយោងអំពីបុគ្គលណាម្នាក់ដែលពុំមែនជាសាច់ញាតិរបស់ខ្លួននិងដែលបានស្គាល់គ្នាយ៉ាងហោចណាស់បីឆ្នាំ។*

ឃ. មិនផ្តល់ភស្តុតាងសមស្របនៃប្រភពចំណូល និងទ្រព្យសម្បត្តិទាំងអស់។

ង. មិនផ្តល់ឯកសារផ្សេងទៀតដែលចាំបាច់សម្រាប់ធ្វើការជ្រើសរើស។

**៧. ការផ្តល់ជូនផ្ទះល្វែងសម្រាប់ជួល**

អ្នកដាក់ពាក្យសុំ នឹងបានទទួលផ្ទះតែមួយល្វែងសម្រាប់ជួល។ ការបដិសេធផ្តល់ជូនផ្ទះល្វែងត្រូវបានចាត់ទុកថា ជាការដកពាក្យសុំរបស់អ្នកដាក់ពាក្យ។

**៨. លក្ខខណ្ឌតម្រូវផ្សេងទៀត។**

ក. គ្មាន

# បញ្ជីពិនិត្យឯកសារសម្រាប់ Wellspring

យើងត្រូវការឯកសារដូចខាងក្រោមដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវ (យើងអាចថតចម្លងសម្រាប់អ្នក)៖

1. ច្បាប់ចម្លងអត្តសញ្ញាណបណ្ណប្រជាពលរដ្ឋ ដែលមានរូបថត សម្រាប់អ្នកដាក់ពាក្យសុំ និងរាល់សមាជិកគ្រួសារពេញវ័យ
2. ច្បាប់ចម្លងនៃបណ្ណសន្តិសុខសង្គមសម្រាប់សមាជិកគ្រួសារទាំងអស់ (ប្រសិនបើមាន)
3. សំបុត្រកំណើតសម្រាប់អនីតិជនទាំងអស់ដែលមានអាយុក្រោម 18 ឆ្នាំ
4. ឯកសារបញ្ជាក់ជម្រើស ប្រសិនបើពុំមានចែងក្នុងឯកសារផ្សេងទៀតដែលមានបញ្ជាក់នៅទីនេះ
5. **ថ្លៃដាក់ពាក្យសុំដែលមិនអាចដកវិញបានចំនួន 25 ដុល្លារ**សម្រាប់អ្នកដាក់ពាក្យ និងរាល់សមាជិកគ្រួសារពេញវ័យដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ ដែលត្រូវបង់មកឱ្យ Wellspring (ជាមូលប្បទានប័ត្រជានាដោយធនាគារ ឬ បណ្ណបញ្ជាទិញសាច់ប្រាក់ តែប៉ុណ្ណោះ។ យើងសូមរក្សាសិទ្ធិមិនទទួលយកមូលប្បទានប័ត្រផ្ទាល់ខ្លួន ឬសាច់ប្រាក់ទេ)។
6. ឯកសារពាក់ព័ន្ធ ដូចមានបញ្ជាក់ខាងក្រោម៖

**ការងារ៖** បង្កាន់ដៃបញ្ជាក់ប្រាក់កម្រៃជាប់ៗគ្នាបីខែចុងក្រោយ សម្រាប់សមាជិកទាំងអស់នៅក្នុងគ្រួសារ ដែលមានអាយុចាប់ពី 18 ឆ្នាំឡើង។ ប្រសិនបើសមាជិកណាម្នាក់បានទទួលកម្រៃជាសាច់ប្រាក់សុទ្ធ គាត់ត្រូវផ្តល់ឯកសារបញ្ជាក់ពីការបង់ពន្ធ ប្រសិនបើបានបង់ពន្ធ។

**ការងារក្នុងរបរផ្ទាល់ខ្លួន៖** ឯកសារបង់ពន្ធ IRS កាលពីឆ្នាំមុន រួមទាំង តារាង C សម្រាប់សមាជិកទាំងអស់ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ នៅក្នុងគ្រួសារ។

**សន្តិសុខសង្គម (SSA)៖** លិខិតដែលទទួលបានចុងក្រោយបំផុត សម្រាប់សមាជិកណាម្នាក់ក្នុងគ្រួសារ។

**បណ្ណសន្តិសុខបន្ថែម (SSI)/ពិការភាព៖** លិខិតឬឯកសារ ដែលចុះកាលបរិច្ឆេទក្នុងរយៈពេល 30 ថ្ងៃចុងក្រោយ សម្រាប់សមាជិកណាម្នាក់ក្នុងគ្រួសារ។

**ភាពគ្មានការងារធ្វើ៖** ឯកសារបញ្ជាក់ប្រាក់ឧបត្ថម្ភឬច្បាប់ចម្លងនៃលិខិតចុងក្រោយ ដែលបង្ហាញចំនួនប្រាក់ឧបត្ថម្ភប្រចាំខែនាពេលបច្ចុប្បន្ន សម្រាប់សមាជិកទាំងអស់ដែលមានអាយុពី 18 ឆ្នាំឡើងទៅ នៅក្នុងគ្រួសារ។

**ជំនួយជាប្រាក់៖** នេះជាអំណោយ ឬ ប្រាក់ដែលទទួលបានជាទៀងទាត់ ពីអ្នកណាម្នាក់នៅក្រៅក្រុមគ្រួសារ (ដោយរាប់បញ្ចូល មនុស្សគ្រប់រូបដែលបង់ថ្លៃវិក្កយបត្រជំនួសអ្នក) សម្រាប់សមាជិកណាម្នាក់ក្នុងគ្រួសារ ដោយមិនគិតពីអាយុឡើយ។ អ្នកបង់អាចតម្រូវឱ្យផ្តល់របាយការណ៍សមតុល្យសាច់ប្រាក់/ទ្រព្យសកម្ម ដែលបង្ហាញពីមូលនិធិ ស្មើនឹងដប់ដងនៃប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ។

**GA/AFDC/TANF៖** លិខិតជូនដំណឹងចុងក្រោយបង្អស់នៃការឧបត្ថម្ភ សម្រាប់សមាជិកណាម្នាក់ក្នុងគ្រួសារ។

**ប្រាក់ឧបត្ថម្ភ/អាហារកិច្ចកុមារ៖** ដីកាតុលាការបច្ចុប្បន្នភាគច្រើន ឬឯកសារបោះពុម្ពដែលបង្ហាញពីប្រវត្តិបង់ប្រាក់ និងឯកសារសង្ខេបសំណុំរឿង។

**គណនីធនាគារ ៖** យើងអាចតម្រូវឱ្យអ្នកផ្តល់របាយការណ៍ចុងក្រោយបំផុតចំនួន 2 ទៅ 6 ដែលជាកម្មសិទ្ធិរបស់សមាជិកណាម្នាក់ក្នុងគ្រួសារ។

**ទ្រព្យផ្សេងទៀត៖** យើងអាចតម្រូវឱ្យអ្នកផ្តល់របាយការណ៍ចុងក្រោយបំផុតចំនួនពីរ ដែលជាកម្មសិទ្ធិរបស់សមាជិកណាម្នាក់នៃគ្រួសារ។ របាយការណ៍នេះរួមបញ្ចូលទាំង 401(k)'s, 403(b)'s, IRA's, ភាគហ៊ុន, លុយគ្រីបតូ និងគណនីដែលកាន់កាប់រួមគ្នាណាមួយ។

**និស្សិត៖** យើងអាចតម្រូវឱ្យសមាជិកគ្រួសារដែលជានិស្សិត ផ្តល់ឯកសារជំនួយហិរញ្ញវត្ថុ និង/ឬ ឯកសារមិនផ្លូវការដែលបញ្ជាក់ពីមុខវិជ្ជាសម្រាប់និស្សិតរូបនោះរៀន។

**ឯកសារផ្សេងទៀត៖** ប្រសិនបើអ្នកមានអចលនទ្រព្យ យើងតម្រូវឱ្យអ្នកផ្តល់បណ្ណកម្មសិទ្ធិ របាយការណ៍អំពីការបញ្ចាំ និងការបង់ពន្ធ។ ប្រសិនបើសមាជិកណាម្នាក់ក្នុងគ្រួសារមានប្រាក់ខែទៀងទាត់ក្នុងនាមជាមន្ត្រីនៃកងកម្លាំងប្រដាប់អាវុធ ប្រាក់បំណាច់បាត់បង់ការងារ ប្រាក់សំណងក្នុងដំណោះស្រាយវិវាទ ប្រាក់ឈ្នះឆ្នោតឬមរតក ប្រាក់បំណាច់មរណភាព ឬ ប្រាក់បំណាច់ពីការធានារ៉ាប់រងអាយុជីវិត ប្រាក់ចំណូលពីមូលនិធិគ្រឹះ ឬ ពីប្រភពចំណូលផ្សេងទៀត សូមផ្តល់ឯកសារដើម្បីអះអាងបញ្ជាក់ប្រភពចំណូលទាំងនោះ។

# Wellspring - ព័ត៌មានអំពីយូ នីតកែសមរម្មួល

**យូនីតសម្រាប់ជនពិការត្រូវបានកែប្រែដូចខាងក្រោម៖**

## សរុបចំនួនប្រាំពីរ (7) យូនីត - 2 បន្ទប់, 3 បន្ទប់

បន្ទប់ទឹក

- អាងងូតទឹកនិងប្រព័ន្ធបញ្ជាដែលអាចអោយរទេះជនពិការចូលបាន
- អាងងូតទឹកមានបំពាក់ក្តាក់ដៃចំនួនពីរសម្រាប់តោង
- អាងងូតទឹកដែលមានក្បាលបើកទឹកនិងក្បាលបង្ហូរទឹកចេញដែលមានភាពងាយស្រួលសំរាប់ជនពិការ
- ទូថ្នាំពេទ្យដែលជនពិការអាចលូកដៃយកបាន
- របារតោងនៅបង្គន់

ផ្ទះបាយ

- ផ្ទះបាយមានច្រកទូលាយដែលអាចអោយរទេះជនពិការចូលបាន
- កុងតាក់ដែលជនពិការអាចបញ្ជាបានសម្រាប់បើកអោយបំពង់បឺតផ្សែង (លើចង្ក្រាន) ដំណើរការបាន
- ព្រីភ្លើងនិងឧបករណ៍បញ្ជាក្នុងផ្ទះបាយដែលងាយស្រួលប្រើសម្រាប់ជនពិការ
- ទូផ្ទះបាយដែលមានកំពស់ 34'' និងមានផ្ទៃរាបទំហំ 30'' សម្រាប់ប្រើជាកន្លែងធ្វើម្ហូប

បន្ទប់ទទួលភ្ញៀវ/បន្ទប់គេង

- ទូដែលមានរបារនិងធ្នើរតាមស្តង់ដារ ADA (របារ/ធ្នើមួយនៅកំពស់ 33" មួយទៀតនៅកំពស់ 63")
- ទ្វារចូលផ្ទះនិងគ្រឿងបំពាក់ជាប់ទ្វារសម្រាប់យូនីតតាមស្តង់ដារ ADA រួមមាន សោរដែលមានដៃទាញ សន្ទះបិទរន្ធសោនិងរន្ធកញ្ចក់មើលពីក្នុងទ្វារមកក្រៅ (រន្ធមួយនៅកំពស់ 43" មួយទៀតនៅកំពស់ 57")

---

**យូនីតសម្រាប់អ្នកគថ្លង់ មានការកែប្រែដូចខាងក្រោម៖**

## សរុបប្រាំពីរ (7) យូនីត - 1 បន្ទប់, 2 បន្ទប់, 3 បន្ទប់

- ប្រព័ន្ធភេរវសញ្ញាអគ្គិភ័យមានបំពាក់ចង្កៀង & ប្រដាប់បំពងសម្លេង (ផ្តល់ទាំងសំឡេងរោទ៍ និងរូបភាព)
- មានកណ្តឹងទ្វារដែលភ្ជាប់ជាមួយនឹងការជូនដំណឹងដែលអាចមើលឃើញ
- ទ្វារចូលផ្ទះនិងគ្រឿងបំពាក់ជាប់ទ្វារសម្រាប់យូនីតតាមស្តង់ដារ ADA រួមមាន សោរដែលមានដៃទាញ សន្ទះបិទរន្ធសោនិងរន្ធកញ្ចក់មើលពីក្នុងទ្វារមកក្រៅ (រន្ធមួយនៅកំពស់ 43" មួយទៀតនៅកំពស់ 57")

---

**ផ្សេងទៀត**

- សរុប 88 យូនីតរួមទាំងយូនីតកែសម្រួលតាមការចាំបាច់ មានរន្ធកញ្ចក់មើលពីក្នុងមកក្រៅទ្វារនៅកម្ពស់ខ្ពស់/ទាប។